

ITTO Project PD 493/07 Rev.1 (F)
"Strengthening Capacity of Forest Law Enforcement and Governance in Cambodia"

# កម្មវិធីបណ្តុះបណ្តាល
# ស្តីពី
# ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ

២០១០


រដ្ឋបាលព្រៃឈើ

អង្គការព្រៃឈើត្រូពិចអន្តរជាតិ_ITTO

# មាតិកា


សេចក្តីថ្លែងអំណរគុណ.....១
អារម្ភកថា.....២
អក្សរកាត់ និង ពាក្យបំព្រួញ.....៣
សេចក្តីសង្ខេប.....៤
សេចក្តីផ្តើម.....៥
គោលបំណង.....៧
លទ្ធផលរំពឹងទុក.....៨
គ្រូបណ្តុះបណ្តាល.....៨
ម៉ូឌុលនៃកម្មវិធីបណ្តុះបណ្តាល.....៨
ម៉ូឌុល ១ : ការបណ្តុះបណ្តាលពិសេស.....១០
១-១ ការប្រមូលផល អនុផលព្រៃឈើ.....១២
១-២ ការចាត់ថ្នាក់ និង កំណត់អត្តសញ្ញាណសត្វព្រៃ.....១២
១-៣ ការហាមឃាត់របស់សាយតេស.....១២
១-៤ បញ្ហាបទល្មើសព្រៃឈើ និង សត្វព្រៃឆ្លងដែន.....១៣
១-៤-១ វេទិកានៃការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និង ពាណិជ្ជកម្ម.....១៣
១-៤-២ វេទិកានៃការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ចអាស៊ីខាងកើត.....១៣
១-៤-៣ វេទិកានៃការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ចអាស៊ាន.....១៣
១-៤-៤ វេទិកានៃបណ្តាញពង្រឹងការអនុវត្តច្បាប់សត្វព្រៃអាស៊ាន.....១៤
ម៉ូឌុល ២ : វិធីនៃការចងក្រងសំណុំរឿងបទល្មើសព្រៃឈើទៅតុលាការៈ ការរៀបចំ និង នីតិវិធី.....១៥
២-១ នីតិវិធីសមស្របសំរាប់ការឃាត់ខ្លួន ឆែកឆេរ ស៊ើបអង្កេត ការប្រមូល និងរក្សាទុកវត្ថុតាង.....១៧
២-១-១ ការឃាត់ខ្លួន.....១៧
២-១-២ ការឆែកឆេរលំនៅដ្ឋាន.....១៧
២-១-៣ ដំណាក់ការនៃការថែរក្សាវត្ថុតាង.....១៧
២-១-៤ ការសួរចម្លើយជនសង្ស័យ និង សាក្សី.....១៧
២-១-៥ បណ្តាញស៊ើបអង្កេត.....១៧
២-១-៦ ការរៀបចំផែនការការងារទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើ.....១៧

២-២ ឯកសារដែលត្រូវការសំរាប់ចងក្រងសំណុំរឿងទៅតុលាការ......១៨
២-៣ ទំរង់របាយការណ៍ស៊ើបអង្កេតដំបូងលើបទល្មើសព្រៃឈើ......១៩
២-៤ លំហាត់អនុវត្ត......១៩
ម៉ូឌុល៣ : ច្បាប់សំខាន់ៗ និង ប្រព័ន្ធតុលាការនៅកម្ពុជា......២០
៣-១ ច្បាប់ស្តីពីព្រៃឈើ ( ជំពូក ១៤-១៧)......២២
៣-២ ច្បាប់ភូមិបាល ( មាត្រា ១៥, ១៦, ១៧, ១៨, ១៩, ២៩, ៣១, ៤៣, ៤៤, ២៥៩)......២៣
៣-៣ ក្រមនីតិវិធីព្រហ្មទណ្ឌ......២៣
៣-៣-១ ប្រព័ន្ធតុលាការនៅកម្ពុជា......២៣
៣-៣-២ អង្គការអយ្យការ......២៤
៣-៣-៣ ចៅក្រមស៊ើបសួរ និង សភាស៊ើបសួរ......២៤
៣-៣-៤ នគរបាលយុត្តិធម៌......២៤
៣-៣-៥ មន្ត្រីនគរបាលយុត្តិធម៌......២៤
៣-៣-៦ ភ្នាក់ងារនគរបាលយុត្តិធម៌......២៥
៣-៣-៧ សាលក្រម និង ការប្តឹងឧទ្ធរណ៍......២៥
៣-៤ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ( ជំពូកទី ១០ : មាត្រា ៥៣-៦៤)......២៥
៣-៥ ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តផ្សេងៗ......២៦
ម៉ូឌុល៤ : ជំនាញពិសេស......២៨
៤-១ ជំនាញទំនាក់ទំនង និង ការចរចារ......៣០
៤-១-១ ជំនាញទំនាក់ទំនង......៣០
៤-១-២ ជំនាញចរចារ......៣០
៤-២ ការគ្រប់គ្រង និង ដោះស្រាយទំនាស់......៣០
៤-៣ ការប្រើប្រាស់ GPS និង មើលផែនទី......៣១
៤-៣-១ ការប្រើប្រាស់ GPS......៣១
៤-៣-២ ការមើលផែនទី......៣១
៤-៤ ការបង្កើត និង គ្រប់គ្រងប្រព័ន្ធទុកដាក់ឯកសារ......៣១
ឯកសារយោង......៣២

# សេចក្តីថ្លែងអំណរគុណ

អ្នករៀបចំកម្មវិធីបណ្តុះបណ្តាលនេះ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម **ទី សុគុន** ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ជាប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ លោកបណ្ឌិត **វ៉ាន់ អ៊ុកម៉ា (Dr. Hwan Ok Ma)** ប្រធានគំរោងអង្គការ **ITTO** លោក **អៀង សារ៉េត** អ្នកសំរបសំរួលគំរោងពង្រឹងសមត្ថភាពការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ចនៅកម្ពុជា និង អ្នកចូលរួមក្នុងកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងកម្មវិធីបណ្តុះបណ្តាលដែលបានប្រព្រឹត្តទៅនៅរដ្ឋបាលព្រៃឈើកាលពីថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០០៩ ព្រមទាំងអស់លោក លោកស្រី អ្នក នាងកញ្ញាដែលមិនបានរៀបរាប់ឈ្មោះ ចំពោះការចូលផ្តល់មតិយោបល់ កែលំអ និង ជួយឧបត្ថម្ភគាំទ្រដ៏មានតំលៃរហូតដល់ការសំរេចបានកម្មវិធីបណ្តុះបណ្តាលនេះ។

# អារម្ភកថា

ព្រៃឈើប្រទេសកម្ពុជាគ្របដណ្តប់ជាងពាក់កណ្តាលនៃផ្ទៃដីប្រទេសនិងជាធនធានធម្មជាតិដ៏សំខាន់បំផុត ប្រព័ន្ធអេកូឡូស៊ីព្រៃឈើទាំងនេះដែលលូតលាស់នៅរយៈកំពស់ផ្សេងៗក្រោមលក្ខខណ្ឌអាកាសធាតុខុសៗគ្នាដែលជាធនធានធម្មជាតិដ៏មានតំលៃមិនអាចកាត់ថ្លៃបាន ។ ព្រៃឈើមិនត្រឹមតែមានមុខងារក្នុងការជួយថែរក្សាលំនឹងប្រពន្ធ័មជ្ឈដ្ឋានធម្មជាតិនិងការពារគុណភាពបរិស្ថានប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជាផងដែរ ។

ក្រោមការដឹកនាំដ៏ត្រឹមត្រូវនិងឈ្លាសវៃបំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង មានការគាំទ្រពីដៃគូអភិវឌ្ឍនានា រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងចាត់វិធានការទប់ស្កាត់ បង្ក្រាប និង លុបបំបាត់បទល្មើសព្រៃឈើគ្រប់ប្រភេទដើម្បីឆ្ពោះទៅដល់ការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព ។ ជាមួយគ្នានេះ ក្នុងនាមជាស្ថាប័នជំនាញរដ្ឋបាលព្រៃឈើបាននឹងកំពុងអនុវត្តគោលនយោបាយកំណែទំរង់វិស័យព្រៃឈើដ៏ស៊ីជំរៅរបស់រាជរដ្ឋាភិបាល ជាពិសេសធ្វើយ៉ាងណាឱ្យការគ្រប់គ្រងព្រៃឈើប្រកបដោយប្រសិទ្ធភាពនិងមានអភិបាលកិច្ចល្អក្នុងវិស័យព្រៃឈើ ។ លទ្ធផលជារួមឃើញថា កំណែទំរង់វិស័យព្រៃឈើកម្ពុជាបាននឹងកំពុងដំណើរការទៅប្រកបដោយជោគជ័យជាបន្តបន្ទាប់ ។

បើទោះជាយ៉ាងណាក្តីនៅក្នុងពេលបច្ចុប្បន្ននេះ កំណែទំរង់វិស័យព្រៃឈើកម្ពុជានៅមានកំណាត់ផ្លូវវែងឆ្ងាយដែលត្រូវអនុវត្តជាបន្តទៀត ។ អង្គការព្រៃឈើត្រូពិចអន្តរជាតិ (ITTO) គឺជាដៃគូមួយរបស់រដ្ឋបាលព្រៃឈើក្នុងការគាំទ្រគំរោងពង្រឹងសមត្ថភាពការអនុវត្តច្បាប់ព្រៃឈើនិងអភិបាលកិច្ច ។ គំរោងនេះក៏បានសិក្សា និង កំណត់អំពីចំនួនមន្ត្រីរដ្ឋបាលព្រៃឈើដែលត្រូវធ្វើការបណ្តុះបណ្តាលការពង្រឹងការអនុវត្តច្បាប់ព្រៃឈើដើម្បីបង្កើនជំនាញនិងបទពិសោធន៍ ព្រមទាំងមុខវិជ្ជាដែលត្រូវការចាំបាច់សំរាប់ការបណ្តុះបណ្តាល ។

កម្មវិធីបណ្តុះបណ្តាលនេះជាលទ្ធផលមួយនៃគំរោងស្តីពីការពង្រឹងសមត្ថភាពការអនុវត្តច្បាប់ព្រៃឈើ និង អភិបាលកិច្ចដែលមានមន្ត្រីរដ្ឋបាលព្រៃឈើមកពីថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋានទូទាំងប្រទេសចូលរួមផ្តល់យោបល់ និង កែលំអរ ហើយកម្មវិធីនេះត្រូវបានរៀបចំនិងបោះពុម្ពដោយរដ្ឋបាលព្រៃឈើក្រោមការជួយឧបត្ថម្ភថវិកាពីអង្គការ ITTO ។ រដ្ឋបាលព្រៃឈើសង្ឃឹមជឿជាក់ថា កម្មវិធីនេះនឹងចូលរួមក្នុងការអភិវឌ្ឍសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើនិងធ្វើឱ្យប្រសើរនូវការកែទំរង់វិស័យព្រៃឈើ ។

ក្នុងនាមរដ្ឋបាលព្រៃឈើ ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះអង្គការ ITTO ដែលជាដៃគូអភិវឌ្ឍដ៏ល្អមួយរបស់រដ្ឋបាលព្រៃឈើហើយសូមប្រសិទ្ធពរជ័យជូនចំពោះលោកអ្នកជួយគាំទ្រទាំងអស់ឱ្យជួបប្រទះនូវសេចក្តីសុខសុភមង្គល និង ជ័យជំនះគ្រប់ប្រការ ។ រដ្ឋបាលព្រៃឈើរង់ចាំទទួលនូវការចូលរួមការផ្តល់មតិយោបល់ស្ថាបនាលើកម្មវិធីបណ្តុះបណ្តាលនេះដើម្បីអនាគតវិស័យព្រៃឈើកម្ពុជា ។

**ឆេង គឹមស៊ុន**

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ**

# អក្សរកាត់ និង ពាក្យបំព្រួញ

| | |
|---|---|
| ASEAN | សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ (អាស៊ាន) |
| ASEAN-FLEG | ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ចតំបន់អាស៊ាន |
| ASEAN-WEN | បណ្តាញការពង្រឹងការអនុវត្តច្បាប់សត្វព្រៃអាស៊ាន |
| CITES | អនុសញ្ញាស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វនិងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ |
| EA- FLEG | ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ចតំបន់អាស៊ីខាងកើត |
| FA | រដ្ឋបាលព្រៃឈើ |
| FLEGT | ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និង ពាណិជ្ជកម្ម |
| GPS | ប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ITTO | អង្គការព្រៃឈើត្រូពិចអន្តរជាតិ |
| UTM | និយាមកា (កូអរដោណេនៃទីតាំងភូមិសាស្ត្រដែលមានអាប់ស៊ីស និង អ៊ីរដោណេ) |

# សេចក្តីសង្ខេប

ដោយមានការគាំទ្រពីអង្គការ ITTO (គំរោង PD493/07 Rev.1(F)) រដ្ឋបាលព្រៃឈើបានរៀបចំកម្មវិធីបណ្តុះបណ្តាល ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើដែលកម្មវិធីនេះនឹងជួយបង្កើនសមត្ថភាពមន្ត្រីពង្រឹងការអនុវត្តច្បាប់របស់រដ្ឋបាលព្រៃឈើតាមរយៈការធ្វើឱ្យប្រសើរនូវការយល់ដឹង និងជំនាញរបស់ពួកគេ។

រដ្ឋបាលព្រៃឈើទទួលស្គាល់ថា ការពង្រឹងការអនុវត្តច្បាប់ពុំទាន់មានប្រសិទ្ធភាពធ្វើឱ្យព្រៃឈើ និងសត្វព្រៃនៅកម្ពុជាមានការថយចុះ។ កម្មវិធីបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងដើម្បីធ្វើឱ្យប្រសើរការពង្រឹងការអនុវត្តច្បាប់ ហើយការរៀបចំកម្មវិធីនេះគឺផ្អែកលើការសិក្សាស្រាវជ្រាវរបស់មន្ត្រីរដ្ឋបាលព្រៃឈើ។

កម្មវិធីបណ្តុះបណ្តាលការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើចែកចេញជាបួនផ្នែក (ម៉ូឌូល) ផ្អែកតាមការវាយតំលៃរបស់រដ្ឋបាលព្រៃឈើកាលពីដើមឆ្នាំ ២០០៩ មានដូចខាងក្រោម :

១- ការសិក្សាពិសេសពាក់ព័ន្ធនឹងបញ្ហាព្រៃឈើ

២- នីតិវិធីសំខាន់ៗទាក់ទងនឹងបទល្មើសព្រៃឈើ

៣- ច្បាប់សំខាន់ៗពាក់ព័ន្ធនឹងការពង្រឹងការអនុវត្តច្បាប់

៤- ជំនាញពិសេស

កម្មវិធីបណ្តុះបណ្តាលនេះនឹងធ្វើការបណ្តុះបណ្តាលមន្ត្រីរដ្ឋបាលព្រៃឈើនៅថ្នាក់កណ្តាលនិងថ្នាក់មូលដ្ឋាន។

## សេចក្តីផ្តើម

នៅពេលដែលបញ្ហានៃការកាប់ឈើខុសច្បាប់ជាបញ្ហាពិភពលោក ប្រទេសកម្ពុជាបានចូលរួមចំណែកយ៉ាងសកម្មនៅក្នុងវេទិកាកិច្ចសហប្រតិបត្តិការព្រៃឈើថ្នាក់តំបន់ និង អន្តរជាតិ រួមមានអង្គការ ITTO និង អង្គការផ្សេងៗទៀតជាច្រើន។ នៅខែតុលា ឆ្នាំ ២០០៤ ក្រុមបេសកកម្មអង្គការ ITTO ចំនួន ០៥ រូប បានចុះពិនិត្យនៅទីវាលជាក់ស្តែងដើម្បីវិភាគបញ្ហាដែលទាក់ទងនឹងគោលបំណងឆ្នាំ ២០០០ របស់អង្គការ ITTO និង ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនៅកម្ពុជា។ ក្រុមបេសកកម្មនេះបានផ្តល់អនុសាសន៍មួយចំនួនពាក់ព័ន្ធនឹងការកាប់ឈើខុសច្បាប់ ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងអភិបាលកិច្ច និងការបង្កើនសមត្ថភាពវិស័យព្រៃឈើកម្ពុជា។

នៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៦ ឯកឧត្តម **ហ្វូមីអាគី តាកាហាស៊ី (Fumiaki Takahashi)** អតីតឯកអគ្គរាជទូតប្រទេសជប៉ុនប្រចាំនៅកម្ពុជាបានចូលរួមក្នុងដំណើរចុះពិនិត្យស្ថានភាពការកាប់ឈើខុសច្បាប់នៅភ្នំឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ ក្រុមការងារចុះពិនិត្យនេះបានធ្វើការពិភាក្សាជាមួយអភិបាលខេត្ត អភិបាលស្រុក អង្គភាពពាក់ព័ន្ធ និង អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការងារនៅទីនោះ។ ឯកឧត្តមឯកអគ្គរាជទូតបានផ្តល់អនុសាសន៍ថាបញ្ហាដែលកើតមានឡើងគួរធ្វើការកំណត់ឱ្យបានច្បាស់លាស់ ហើយធ្វើការដោះស្រាយបញ្ហាទាំងនោះ។

អនុលោមតាមអនុសាសន៍របស់ឯកឧត្តមឯកអគ្គរាជទូត គំរោងបឋម ITTO (PPD 128/06 Rev.1 (F) ត្រូវបានរៀបចំស្នើ និង អនុមត័ផ្តល់ថវិកាដោយអង្គការ ITTO។ ផ្អែកលើពត៌មានដែលចុះស្រាវជ្រាវដោយអ្នកស្រាវជ្រាវចំនួនពីររូប និង សិក្ខាសាលាថ្នាក់ជាតិចំនួនពីរលើកក្នុងអំឡុងពេលអនុវត្តគំរោងសំណើបឋមនោះបានបញ្ជាក់ថា គំរបព្រៃឈើថយចុះគឺបណ្តាលមកពីបញ្ហានៃការកាប់រាន និង ហ៊ុំព័ទ្ធវាតយកដីព្រៃឈើធ្វើកម្មសិទ្ធិខុសច្បាប់ ការកាប់ឈើខុសច្បាប់ ការគ្រប់គ្រងមិនទាន់សមស្រប ការដាំឈើឡើងវិញនៅមានកំរិត និង កំណើនប្រជាពលរដ្ឋ ដែលមូលហេតុទាំងអស់នេះដោយសារការពង្រឹងការអនុវត្តច្បាប់មិនទាន់បានតឹងរឹងនៅឡើយ។ មានបញ្ហាចំបងៗចំនួនប្រាំនៃការពង្រឹងការអនុវត្តច្បាប់មិនទាន់បានល្អដូចជា សំភារៈ-បរិក្ខាមានកំរិត មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលការបណ្តុះបណ្តាលការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើមិនគ្រប់គ្រាន់ ការតាមដានត្រួតពិនិត្យបទល្មើសព្រៃឈើនៅមានកំរិត នីតិវិធីតាមផ្លូវតុលាការមិនទាន់មានប្រសិទ្ធភាព និង ការចូលរួមពីមូលដ្ឋានមិនទាន់បានទូលំទូលាយ។

លទ្ធផលនៃការសិក្សាស្រាវជ្រាវចំនួនពីរលើកតាមរយៈការសំភាសន៍ជាមួយអ្នកពាក់ព័ន្ធចំនួន ៥៧០នាក់ (មន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋានចំនួន ៣០០នាក់ និង អ្នកពាក់ព័ន្ធចំនួន ២៧០នាក់) នៅពេលអនុវត្តគំរោងបឋមបានបង្ហាញថា ក្នុងចំណោមអ្នកផ្តល់សំភាសន៍ទាំងនោះគឺ ៩៦%ផ្តល់យោបល់ថាខ្វះសំភារៈ-បរិក្ខា ហើយ ៩៨% ទៀតផ្តល់យោបល់ថា ត្រូវការបង្កើនសមត្ថភាពតាមរយៈការបណ្តុះបណ្តាលការយល់ដឹងឱ្យបានទូលំទូលាយ។

ផ្តើមចេញពីគំរោងសំណើបឋមរបស់អង្គការ ITTO នេះ អង្គការ ITTO បានអនុម័តលើគំរោងសំណើ ដែលបានស្នើដោយរដ្ឋបាលព្រៃឈើគឺគំរោងអង្គការ ITTO លេខ PD493/07 Rev.1 (F) មានឈ្មោះថា **គំរោងពង្រឹងសមត្ថភាពការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ចនៅកម្ពុជា** ដែលចាប់ផ្តើមអនុវត្តនៅខែមករា ឆ្នាំ ២០០៩ នេះ។

ដើម្បីបង្កើនសមត្ថភាពនៃការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ ដែលជាមូលហេតុសំខាន់មួយនៃការពង្រឹងការអនុវត្តច្បាប់មិនទាន់សមស្របនោះ រដ្ឋបាលព្រៃឈើក៏បានធ្វើការសិក្សាវាយតំលៃអង្គភាពរបស់ខ្លួន។ ការសិក្សាស្រាវជ្រាវថ្មីៗចំនួនពីរត្រូវបានធ្វើនៅឆ្នាំ ២០០៩ នេះ ដើម្បីកំណត់ចំនួនមន្ត្រីរដ្ឋបាលព្រៃឈើ និង មុខវិជ្ជាសំរាប់ការបណ្តុះបណ្តាល។ លទ្ធផលនៃការសិក្សាទីមួយមាននៅក្នុង "របាយការណ៍វាយតំលៃធនធានមនុស្សនៅរដ្ឋបាលព្រៃឈើថ្នាក់មូលដ្ឋានដែលត្រូវធ្វើការបណ្តុះបណ្តាល" (ការសិក្សារបស់លោក **ពិន ផាន់នី** នៅខែមីនា ឆ្នាំ ២០០៩)។ ចំពោះការសិក្សានេះ អ្នកសិក្សាបានជួបជាមួយមន្ត្រីខ័ណ្ឌរដ្ឋបាលព្រៃឈើចំនួន ១១ តាមរយៈការឆ្លើយទៅនឹងសំណួរវាយតំលៃតំរូវការនៃការបណ្តុះបណ្តាលរបស់ពួកគេ។ ផ្អែកលើពត៌មានដែលបានទទួលពីបញ្ជីសំណួរទាំងនេះ របាយការណ៍បានផ្តល់អនុសាសន៍ (ចំណោមបញ្ហាផ្សេងៗ)ថា រដ្ឋបាលព្រៃឈើគួរធ្វើការបណ្តុះបណ្តាលមន្ត្រីបង្គោលលើជំនាញពាក់ព័ន្ធនឹងការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ។ បន្ទាប់មក មន្ត្រីបង្គោលដែលបានទទួលការបណ្តុះបណ្តាលទាំងនេះនឹងទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលបន្តដល់មន្ត្រីផ្នែក និង សង្កាត់រដ្ឋបាលព្រៃឈើក្នុងគោលបំណងដើម្បីបង្កើនសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើផង និង កាត់បន្ថយការចំណាយជួលគ្រូបណ្តុះបណ្តាលពីខាងក្រៅរដ្ឋបាលព្រៃឈើផង។ របាយការណ៍ក៏បានផ្តល់អនុសាសន៍ដែរថា មុខវិជ្ជាមួយចំនួនដែលគួរបញ្ចូលក្នុងការបណ្តុះបណ្តាលរួមមាន :

- ការតាមដាន ការស៊ើបអង្កេត និង ការប្រមូលពត៌មានបទល្មើសព្រៃឈើ
- ការវិភាគ និង ការផ្ទៀងផ្ទាត់ពត៌មានបទល្មើសព្រៃឈើដែលបានទទួល
- ការរៀបចំផែនការ និង ការចាត់វិធានការទប់ស្កាត់ និង បង្ក្រាបសកម្មភាពបទល្មើសព្រៃឈើ
- ការប្រើប្រាស់ឧបករណ៍ GPS និង ផែនទីព្រៃឈើ
- នីតិវិធីនៃការចងក្រងសំណុំរឿងបទល្មើសព្រៃឈើទៅតុលាការ
- សេចក្តីពន្យល់អំពីដំណើរការរបស់តុលាការ

របាយការណ៍ក៏បានសំណូមពរឱ្យមានការសិក្សាស្រាវជ្រាវបន្ថែមទៀត អំពីមុខវិជ្ជាសំខាន់ៗសំរាប់បង្កើនសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន។ នៅខែមេសា ឆ្នាំ ២០០៩ លោក **សួន សុវណ្ណ** បានធ្វើការសិក្សាស្រាវជ្រាវអំពីថាតើមុខវិជ្ជាអ្វីខ្លះដែលត្រូវការចាំបាច់សំរាប់ការបណ្តុះបណ្តាលមន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន ហើយជាលទ្ធផលនៃការសិក្សាស្រាវជ្រាវ លោកបានផ្តល់អនុសាសន៍ថាមុខវិជ្ជាសំខាន់ៗមួយចំនួនដូចខាងក្រោមគួរបញ្ចូលក្នុងការបណ្តុះបណ្តាលរួមមាន :

- ក្រមនីតិវិធីព្រហ្មទណ្ឌ
- នីតិវិធីនៃការប្តឹងទៅសាលាជំរះក្តីគ្រប់ជាន់ថ្នាក់ និង ការបញ្ចប់សំណុំរឿងបទល្មើសព្រៃឈើ
- ការប្រើប្រាស់ឧបករណ៍ GPS និង ផែនទី
- ការគ្រប់គ្រង និង ដោះស្រាយទំនាស់បទល្មើសព្រៃឈើ
- នីតិវិធីនៃការស្រាវជ្រាវ ស៊ើបអង្កេត ឃាត់ខ្លួន និង ដកហូតវត្ថុតាង
- នីតិវិធីនៃការស្រង់ស្ថិតិ និងដកហូតដីព្រៃដែលបានកាប់រានទិញទំព័ទ្ធដោយខុសច្បាប់មកជាសម្បត្តិរដ្ឋ
- ការរៀបចំផែនការទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើ
- នីតិវិធីនៃការចងក្រងសំណុំរឿងបទល្មើសព្រៃឈើ និង ការទុកដាក់ឯកសារ
- ការកំណត់អត្តសញ្ញាណសត្វព្រៃ
- នីតិវិធីនៃការធ្វើរបាយការណ៍ស៊ើបអង្កេតដំបូងលើបទល្មើសព្រៃឈើ
- ជំនាញទំនាក់ទំនង
- ច្បាប់ស្តីពីព្រៃឈើ
- នីតិវិធីនៃការចាត់ចែងវត្ថុតាងបទល្មើសព្រៃឈើ និង ការដោះលែងមធ្យោបាយប្រព្រឹត្តបទល្មើស
- ប្រភេទរុក្ខជាតិ និង សត្វព្រៃដែលហាមឃាត់ការធ្វើពាណិជ្ជកម្មដោយអនុសញ្ញាសាយតេស
- ច្បាប់ភូមិបាល

ដើម្បីពង្រឹងសមត្ថភាពនៃការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ច គឺចាំបាច់ណាស់ត្រូវបង្កើតកម្មវិធីបណ្តុះបណ្តាលសំរាប់ធ្វើការបំពាក់បំប៉នមន្ត្រីរដ្ឋបាលព្រៃឈើ ហើយកម្មវិធីបណ្តុះបណ្តាលនេះនឹងប្រព្រឹត្តទៅតាមគោលបំណងកំណត់ និង លទ្ធផលរំពឹងទុក។

## គោលបំណង

គោលបំណងនៃកម្មវិធីបណ្តុះបណ្តាលគឺធ្វើការណែនាំសិក្ខាកាម :

- សិក្សាច្បាប់សំខាន់ៗមួយចំនួន និង លិខិតបទដ្ឋានគតិយុត្តសំរាប់ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ
- ស្វែងយល់អំពីប្រព័ន្ធតុលាការនៅកម្ពុជា
- យល់ដឹងអំពីនីតិវិធីត្រឹមត្រូវសំរាប់ការឆែកឆេរ ការស្រាវជ្រាវ ការស៊ើបអង្កេត ការចងក្រងសំណុំរឿងបទល្មើសទៅតុលាការ ការធ្វើសេចក្តីរាយការណ៍បទល្មើស ការរៀបចំផែនការទប់ស្កាត់ និង បង្ក្រាបបទល្មើស ការថែរក្សាទុក និងចាត់ចែងវត្ថុតាងបទល្មើស
- យល់ដឹងអំពីបណ្តាញការងារផ្សេងៗពាក់ព័ន្ធនឹងបញ្ហាបទល្មើសឆ្លងដែនដូចជាការកាប់ឈើខុសច្បាប់ ការធ្វើពាណិជ្ជកម្មឈើ និង សត្វព្រៃខុសច្បាប់
- យល់ដឹងអំពីនីតិវិធីសំរាប់ការធ្វើអាជីវកម្មឈើត្រឹមត្រូវ និង ការតាមដានការធ្វើអាជីវកម្ម

- យល់ដឹងអំពីភាពខុសគ្នារវាងក្រុមប្រភេទសត្វព្រៃជិតផុតពូជ ក្រុមប្រភេទសត្វព្រៃមានដោយកម្រ
- និង ក្រុមប្រភេទសត្វព្រៃមានដោយបង្គួរ និង ការកំណត់អត្តសញ្ញាណសត្វព្រៃ។

## លទ្ធផលរំពឹងទុក

នៅចុងបញ្ចប់នៃកម្មវិធីបណ្តុះបណ្តាល សិក្ខាកាមនឹងទទួលបានពីវគ្គបណ្តុះបណ្តាលដូចខាងក្រោម :

- បង្កើនការយល់ដឹងអំពីច្បាប់ស្តីពីព្រៃឈើ ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងច្បាប់ស្តីពីព្រៃឈើ
- មានសមត្ថភាព និង ប្រសិទ្ធភាពក្នុងការឆែកឆេរ ការស្រាវជ្រាវ ការស៊ើបអង្កេត ការធ្វើសេចក្តីរាយការណ៍ និង ការចងក្រងសំណុំរឿងបទល្មើសព្រៃឈើ
- បង្កើនការយល់ដឹងទូទៅអំពីការហាមឃាត់ការធ្វើអាជីវកម្មឈើ ការបរបាញ់ ការដឹកជញ្ជូន និង ការធ្វើពាណិជ្ជកម្មសត្វព្រៃ
- បង្កើនការយល់ដឹងអំពីការប្រើប្រាស់ឧបករណ៍ GPS និង ផែនទីក្នុងការកំណត់ទីតាំងបទល្មើសព្រៃឈើ
- បង្កើនការយល់ដឹងអំពីជំនាញនៃការគ្រប់គ្រង និងដោះស្រាយទំនាស់ និង ការទំនាក់ទំនង
- យល់ដឹងអំពីការគ្រប់គ្រងឯកសារ

## គ្រូបណ្តុះបណ្តាល

ដើម្បីសមត្ថភាព និង ប្រសិទ្ធភាពសំរាប់កម្មវិធីបណ្តុះបណ្តាលនេះ គឺចាំបាច់ត្រូវការគ្រូបណ្តុះបណ្តាលមានវិជ្ជាជីវៈមកពីរដ្ឋបាលព្រៃឈើ និង ក្រសួង-ស្ថាប័នផ្សេងៗដូចជា ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្រសួងបរិស្ថាន ក្រសួងយុត្តិធម៌ និង អ្នកជំនាញការអន្តរជាតិ ។ល។

## ម៉ូឌុលនៃកម្មវិធីបណ្តុះបណ្តាល

កម្មវិធីបណ្តុះបណ្តាលនេះចែកចេញជាបួនម៉ូឌុលគឺ :

១- ការសិក្សាពិសេសពាក់ព័ន្ធនឹងបញ្ហាព្រៃឈើ (ការធ្វើអាជីវកម្មឈើ ការកំណត់អត្តសញ្ញាណសត្វព្រៃ អនុសញ្ញាសាយតេស និង បញ្ហាបទល្មើសឆ្លងដែនផ្សេងៗ)

២- នីតិវិធីសំខាន់ៗទាក់ទងនឹងបទល្មើសព្រៃឈើ ( ការឆែកឆេរ ការស៊ើបអង្កេត ការប្រមូលវត្ថុតាង ចងក្រងសំណុំរឿងបទល្មើសព្រៃឈើទៅតុលាការ និង រដ្ឋបាលព្រៃឈើថ្នាក់កណ្តាល)

៣- ច្បាប់សំខាន់ៗពាក់ព័ន្ធនឹងការពង្រឹងការអនុវត្តច្បាប់ (ច្បាប់ស្តីពីព្រៃឈើ ច្បាប់ភូមិបាល ក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តផ្សេងៗ)

៤- ជំនាញពិសេស (ការទំនាក់ទំនង ការចរចារ ការគ្រប់គ្រងនិងការដោះស្រាយទំនាស់ ការប្រើប្រាស់ឧបករណ៍ GPS និងផែនទី និង ការគ្រប់គ្រងឯកសារ)។

ការបណ្តុះបណ្តាលនេះនឹងធ្វើការបណ្តុះបណ្តាលដល់មន្ត្រីរដ្ឋបាលព្រៃឈើគ្រប់កំរិតនៅថ្នាក់កណ្តាល និង ថ្នាក់ មូលដ្ឋាន (អធិការដ្ឋាន ខ័ណ្ឌ ផ្នែក និង សង្កាត់រដ្ឋបាលព្រៃឈើ) រួមបញ្ចូលទាំងទ្រឹស្តី និង ការអនុវត្តនៅទីវាល។

## ម៉ូឌុល ១ : ការបណ្តុះបណ្តាលពិសេស (មានរយៈពេល ២ថ្ងៃក្នុងនោះ ១,៥ ថ្ងៃសិក្សាក្នុងថ្នាក់ និង ០,៥ ថ្ងៃចុះកម្មសិក្សារួមជាមួយលំហាត់សំរាប់ម៉ូឌុល ៤)

**មុខវិជ្ជាដែលត្រូវបណ្តុះបណ្តាលរួមមាន :**

១- ការប្រមូលផល អនុផលព្រៃឈើ

២- ការកំណត់អត្តសញ្ញាណសត្វព្រៃ

៣- ការហាមឃាត់របស់អង្គការសាយតេស

៤- បញ្ហាបទល្មើសព្រៃឈើ និង សត្វព្រៃឆ្លងដែនខុសច្បាប់ (FLEGT, EA FLEG, ASEAN FLEG, ASEAN-WEN)

**គោលដៅនៃវគ្គ/គោលបំណងនៃការសិក្សា**

- ដើម្បីយល់ដឹងអំពីនីតិវិធីសំរាប់ការប្រមូលផល អនុផលព្រៃឈើត្រឹមត្រូវ តំរូវការលិខិតអនុញ្ញាត និង វិធីសាស្រ្តក្នុងការតាមដានត្រួតពិនិត្យការប្រមូលផល អនុផលព្រៃឈើ
- ដើម្បីយល់ដឹងអំពីភាពខុសគ្នារវាងក្រុមប្រភេទសត្វព្រៃជិតផុតពូជ ក្រុមប្រភេទសត្វព្រៃមានដោយកម្រ និង ក្រុមប្រភេទសត្វព្រៃមានដោយបង្គួរ និងធ្វើការកំណត់អត្តសញ្ញាណសត្វព្រៃ
- ដើម្បីស្វែងយល់អំពីភាពខុសគ្នារវាងបណ្តាញការងារផ្សេងៗពាក់ព័ន្ធនឹងបញ្ហាបទល្មើសព្រៃឈើ និង សត្វព្រៃឆ្លងដែនខុសច្បាប់ដូចជា ការកាប់ឈើខុសច្បាប់ ការធ្វើពាណិជ្ជកម្មឈើ និង សត្វព្រៃខុសច្បាប់ ។

**គោលបំណងសំរេចបាន**

នៅចុងបញ្ចប់នៃវគ្គនេះ សិក្ខាកាមអាចនឹងៈ

- យល់ដឹងអំពីនីតិវិធី និង ការតាមដានត្រួតពិនិត្យការប្រមូលផល អនុផលព្រៃឈើដែលទទួលបានការអនុញ្ញាត
- ស្គាល់អំពីប្រភេទសត្វព្រៃជិតផុតពូជ ប្រភេទសត្វព្រៃមានដោយកំរ និង ប្រភេទសត្វព្រៃមានដោយបង្គួរដែលមាននៅក្នុងប្រទេសកម្ពុជា
- យល់ដឹងអំពីវេទិកាតំបន់ និង អន្តរជាតិពាក់ព័ន្ធនឹងបទល្មើសព្រៃឈើ និងសត្វព្រៃឆ្លងដែនខុសច្បាប់ ។

**វិធីសាស្រ្តនៃការបណ្តុះបណ្តាល**

វិធីសាស្រ្តក្នុងការបណ្តុះបណ្តាលរួមមានការឧទ្ទេសនាម ឯកសារមេរៀន សំណួរនិងចម្លើយ លំហាត់អនុវត្តស្តីពីការប្រមូលផល អនុផលព្រៃឈើ ការធ្វើការងារជាក្រុម ការចុះកម្មសិក្សាជាមួយនឹងការធ្វើតេសអនុវត្តឧទាហរណ៍ និង ការពន្យល់ ។

**សំភារៈ និង ឧបករណ៍អនុវត្ត**

- ថ្នាក់រៀន
- ក្ដារខៀន
- កុំព្យូទ័រយួរដៃ និង ឧបករណ៍បញ្ចាំងស្លាយ
- ប្រកាសលេខ ០៨៩ ប្រក.កសក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ដីពីផល អនុផលព្រៃឈើដែលត្រូវហាមឃាត់ការប្រមូលផល
- ក្រមបច្ចេកទេសអនុវត្តប្រមូលព្រៃឈើនៅកម្ពុជា
- គោលការណ៍ណែនាំសំរាប់ធ្វើអត្តសញ្ញាណសត្វព្រៃនៅកម្ពុជា
- ប្រកាសលេខ ០២០ ប្រក.កសក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ដីពីចំណាត់ថ្នាក់ និង បញ្ជីឈ្មោះប្រភេទសត្វព្រៃ
- ប្រកាសលេខ ៥៥០ ប្រក.កសក ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ដីពីការកែសំរួលការកែសំរួលឈ្មោះប្រភេទសត្វព្រៃចំនួន ៥ប្រភេទ និង ធ្វើចំណាត់ថ្នាក់សត្វព្រៃចំនួន ៦ប្រភេទ ក្នុងឧបសម្ព័ន្ធនៃប្រកាសលេខ ០២០ ប្រក.កសក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- ឯកសារអំពីវេទិកាតំបន់ និង អន្តរជាតិពាក់ព័ន្ធនឹងបទល្មើសព្រៃឈើ និងសត្វព្រៃឆ្លងដែនខុសច្បាប់ ។

**ការវាយតំលៃ**

- វគ្គសំណួរ និង ចម្លើយអំពីចំណុចសំខាន់ៗដែលកើតឡើង
- កម្មសិក្សានៅឧទ្យានសួនសត្វ និង មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ

## ១-១ ការប្រមូលផល អនុផលព្រៃឈើ

នីតិវិធីនៃការប្រមូលផល អនុផលព្រៃឈើមានបញ្ញត្តិក្នុងជំពូកទី៨នៃច្បាប់ស្តីពីព្រៃឈើ និងប្រកាសលេខ ០៨៩ ប្រក.កសក ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីផល អនុផលព្រៃឈើដែលត្រូវហាមឃាត់ការប្រមូលផល និង ក្រមបច្ចេកទេសប្រមូលផល អនុផលព្រៃឈើនៅកម្ពុជា។

គ្រូបណ្តុះបណ្តាលនឹងបង្រៀនសិក្ខាកាមអំពី ៖

- នីតិវិធីសំរាប់ការប្រមូលផល អនុផលព្រៃឈើត្រឹមត្រូវ
- ប្រព័ន្ធត្រួតពិនិត្យឈើស្របច្បាប់
- សិទ្ធិប្រើប្រាស់ជាប្រពៃណី និង សហគមន៍ព្រៃឈើ

គ្រូបណ្តុះបណ្តាលនឹងផ្តល់លំហាត់ផងដែរស្តីពីការប្រមូលផល អនុផលព្រៃឈើដល់សិក្ខាកាមដើម្បីធ្វើការពិភាក្សាជាក្រុម។

## ១-២ ការចាត់ថ្នាក់ និង កំណត់អត្តសញ្ញាណសត្វព្រៃ

គ្រូបណ្តុះបណ្តាលនឹងផ្តល់ពតិមានដល់សិក្ខាកាមអំពី ៖

- ការចាត់ថ្នាក់សត្វព្រៃ
- ការកំណត់អត្តសញ្ញាណសត្វព្រៃ
- ការព្យាបាលដោយត្រឹមត្រូវចំពោះសត្វព្រៃដែលបានចាប់ឃាត់

## ១-៣ ការហាមឃាត់របស់សាយតេស

អនុសញ្ញាស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វនិងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ (សាយតេស) គឺជាអនុសញ្ញាអន្តរជាតិរវាងរដ្ឋាភិបាល។ គោលបំណងនៃអនុសញ្ញានេះគឺការធ្វើឱ្យប្រាកដថា ការធ្វើពាណិជ្ជកម្មអន្តរជាតិចំពោះសំណាកសត្វព្រៃ និង រុក្ខជាតិ មិនគំរាមកំហែងដល់ការរស់រានមានជីវិតនៃប្រភេទសត្វ និង រុក្ខជាតិព្រៃ។

គ្រូបណ្តុះបណ្តាលនឹងនាំសិក្ខាកាមឱ្យយល់ដឹងអំពី ៖

- ការពិពណ៌នាអំពីសាយតេស
- គោលបំណងនៃសាយតេស
- ផលប្រយោជន៍នៃសាយតេស
- គ្រោងការ និង រចនាសម្ព័ន្ធនៃសាយតេស
- សមត្ថកិច្ច (អាជ្ញាធរ) គ្រប់គ្រងសាយតេសកម្ពុជា

- អនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និង រុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់

## ១-៤ បញ្ហាបទល្មើសព្រៃឈើ និង សត្វព្រៃឆ្លងដែន

ដើម្បីធ្វើឱ្យប្រសើរការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ច មានវេទិកាជាច្រើនត្រូវបានបង្កើតឡើងក្នុងការប្រយុទ្ធប្រឆាំងនឹងការកាប់ឈើខុសច្បាប់ ការធ្វើពាណិជ្ជកម្មឈើ និង សត្វព្រៃខុសច្បាប់ ដើម្បីគ្រប់គ្រងព្រៃឈើ និង ផលិតកម្មឈើប្រកបដោយនិរន្តរភាព។

គ្រូបណ្តុះបណ្តាលនឹងបង្ហាញសិក្ខាកាមអំពី :

### ១-៤-១ វេទិកានៃការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និង ពាណិជ្ជកម្ម (FLEGT)

- ការពិពណ៌នាអំពីវេទិកានៃការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និង ពាណិជ្ជកម្ម
- គោលបំណងនៃវេទិកាពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និង ពាណិជ្ជកម្ម
- ផលប្រយោជន៍នៃវេទិកាពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និង ពាណិជ្ជកម្ម
- គ្រោងការ និង រចនាសម្ព័ន្ធនៃវេទិកាពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្ម
- តួនាទី ការចូលរួម និង បណ្តាញការងាររបស់កម្ពុជាជាមួយវេទិកាពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និងពាណិជ្ជកម្ម

### ១-៤-២ វេទិកានៃការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ចអាស៊ីខាងកើត (EA FLEGT)

- ការពិពណ៌នាអំពីវេទិកាការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ចអាស៊ីខាងកើត
- គោលបំណងនៃវេទិកាពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ចអាស៊ីខាងកើត
- ផលប្រយោជន៍នៃវេទិកាពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ចអាស៊ីខាងកើត
- គ្រោងការ និង រចនាសម្ព័ន្ធនៃវេទិកាពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ចអាស៊ីខាងកើត
- តួនាទី ការចូលរួម និង បណ្តាញការងាររបស់កម្ពុជាជាមួយវេទិកាពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ចអាស៊ីខាងកើត

### ១-៤-៣ វេទិកានៃការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ចអាស៊ាន (ASEAN FLEGT)

- ការពិពណ៌នាអំពីវេទិកានៃការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងអភិបាលកិច្ចអាស៊ាន
- គោលបំណងនៃវេទិកាពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ចអាស៊ាន
- ផលប្រយោជន៍នៃវេទិកាពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ចអាស៊ាន
- គ្រោងការ និង រចនាសម្ព័ន្ធនៃវេទិកាពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងអភិបាលកិច្ចអាស៊ាន

- តួនាទី ការចូលរួម និង បណ្តាញការងាររបស់កម្ពុជាជាមួយវេទិកាពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ចអាស៊ាន

**១-៤-៤ វេទិកានៃបណ្តាញពង្រឹងការអនុវត្តច្បាប់សត្វព្រៃអាស៊ាន (ASEAN-WEN)**

- ការពិពណ៌នាអំពីវេទិកានៃបណ្តាញពង្រឹងការអនុវត្តច្បាប់សត្វព្រៃអាស៊ាន
- គោលបំណងនៃវេទិកាបណ្តាញពង្រឹងការអនុវត្តច្បាប់សត្វព្រៃអាស៊ាន
- ផលប្រយោជន៍នៃវេទិកាបណ្តាញពង្រឹងការអនុវត្តច្បាប់សត្វព្រៃអាស៊ាន
- គ្រោងការ និង រចនាសម្ព័ន្ធនៃវេទិកាបណ្តាញពង្រឹងការអនុវត្តច្បាប់សត្វព្រៃអាស៊ាន
- តួនាទី ការចូលរួម និង បណ្តាញការងាររបស់កម្ពុជាជាមួយវេទិកាបណ្តាញពង្រឹងការអនុវត្តច្បាប់សត្វព្រៃអាស៊ាន

## ម៉ូឌុល ២ ៖ វិធីនៃការចងក្រងសំណុំរឿងបទល្មើសព្រៃឈើទៅតុលាការ ៖ ការរៀបចំ និង នីតិវិធី (មានរយៈពេល២ថ្ងៃក្នុងនោះ ១ថ្ងៃកន្លះសិក្សាក្នុងថ្នាក់ និង កន្លះថ្ងៃចុះកម្មសិក្សា)

**មុខវិជ្ជាដែលត្រូវបណ្តុះបណ្តាលរួមមាន ៖**

១- នីតិវិធីសមស្របសំរាប់ការឆែកឆេរ ការស្រាវជ្រាវ ការស៊ើបអង្កេត ការប្រមូល និងរក្សាទុកវត្ថុតាងបទល្មើស (គំរូវិការដីកា ការចាប់ឃាត់វត្ថុតាងនិងការចងក្រងសំណុំរឿងបទល្មើស បណ្តាញស៊ើបអង្កេត ការរៀបចំផែនការទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើ)

២- សំណុំឯកសារត្រូវការសំរាប់ការចងក្រងសំណុំរឿង (គំរូលិខិតដែលត្រូវការដោយតុលាការ)

៣- របាយការណ៍ស៊ើបអង្កេតដំបូងលើបទល្មើសព្រៃឈើសំរាប់ប្រព័ន្ធតាមដានពត៌មានបទល្មើសព្រៃឈើ (គំរូរបាយការណ៍របស់ផ្នែកតាមដាន និង រាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ)

**គោលដៅនៃវគ្គ/គោលបំណងនៃការសិក្សា**

- ដើម្បីយល់ដឹងអំពីនីតិវិធីត្រឹមត្រូវសំរាប់ការចាប់ខ្លួន
- ដើម្បីយល់ដឹងអំពីនីតិវិធីត្រឹមត្រូវសំរាប់ការឆែកឆេរ និង ការចាប់ឃាត់
- ដើម្បីយល់ដឹងអំពីនីតិវិធីត្រឹមត្រូវសំរាប់ការចងក្រងសំណុំរឿងទៅតុលាការ
- ដើម្បីយល់ដឹងអំពីការរៀបចំបណ្តាញស៊ើបអង្កេត និងការប្រើប្រាស់ពត៌មានដែលបានទទួលពីបណ្តាញស៊ើបអង្កេត
- ដើម្បីយល់ដឹងអំពីការរៀបចំផែនការទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើ
- ដើម្បីសិក្សាអំពីវិធីនៃការស្វែងរក និង រក្សាទុកវត្ថុតាងបទល្មើស
- ដើម្បីយល់ដឹងអំពីថាតើពេលណាដែលវត្ថុតាងអាចប្រគល់ជូនម្ចាស់វិញ
- ដើម្បីសិក្សាអំពីវិធីបំពេញគំរូលិខិត និង រៀបចំឯកសារផ្សេងៗសំរាប់ករណីតុលាការ

**គោលបំណងសំរេចបាន**

នៅចុងបញ្ចប់នៃវគ្គនេះសិក្ខាកាមនឹងទទួលបាននូវ៖

- ការពន្យល់ថាតើនៅពេលណាដែលត្រូវការដីកាពីតុលាការសំរាប់ការឃាត់ខ្លួន ការឆែកឆេរ និង ការចាប់ឃាត់បទល្មើស
- ការពិពណ៌នាអំពីនីតិវិធីសំរាប់ការចងក្រងសំណុំរឿងទៅតុលាការ
- ការពិពណ៌នាអំពីដំណាក់កាលនីមួយៗនៃការស៊ើបអង្កេត
- ការរៀបចំផែនការនៃការស៊ើបអង្កេត និង ផែនការទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើ
- ការបង្កើតបណ្តាញស៊ើបអង្កេតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

- ការពន្យល់អំពីវិធីនៃការថែរក្សា និង រៀបចំឯកសារវត្ថុតាង
- ការយល់ដឹងពីការសួរចម្លើយជនសង្ស័យ និង សាក្សី
- ការបំពេញទំរង់លិខិត និង ឯកសារផ្សេងៗដែលត្រូវការសំរាប់ការចងក្រងសំណុំរឿងទៅតុលាការ
- ការបំពេញរបាយការណ៍ស៊ើបអង្កេតដំបូងអំពីបទល្មើសព្រៃឈើសំរាប់ប្រព័ន្ធតាមដានពតិមានបទល្មើសព្រៃឈើរបស់ផ្នែកតាមដាន និង រាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ (រដ្ឋបាលព្រៃឈើ)។

## វិធីសាស្ត្រនៃការបណ្តុះបណ្តាល

វិធីសាស្ត្រក្នុងការបណ្តុះបណ្តាលរួមមានការឧទ្ទេសនាម ឯកសារមេរៀន លំហាត់ សំណួរនិងចម្លើយ លំហាត់អនុវត្ត ការធ្វើការងារជាក្រុម ឧទាហរណ៍ និង ការពន្យល់

## សំភារៈ និង ឧបករណ៍អនុវត្ត

- ថ្នាក់រៀន
- ក្តារខៀន
- កុំព្យូទ័រយួរដៃ និង ឧបករណ៍បញ្ចាំងស្លាយ
- គំរូលិខិតដែលត្រូវការសំរាប់បំពេញទៅតុលាការ
- គំរូរបាយការណ៍ស៊ើបអង្កេតដំបូងលើបទល្មើសព្រៃឈើ
- បញ្ជីសំណួរសំរាប់សួរចម្លើយ
- លំហាត់អនុវត្ត

## ការវាយតំលៃ

- ការសំដែង (ការដើរតួសំដែង) អំពីការសួរចម្លើយជនសង្ស័យ និង សាក្សី
- លំហាត់អំពីការរៀបចំចងក្រងសំណុំរឿងទៅតុលាការ
- លំហាត់អនុវត្ត និង ពិភាក្សាក្រុម
- លំហាត់អំពីការរៀបចំរបាយការណ៍ស៊ើបអង្កេតដំបូងលើបទល្មើសព្រៃឈើសំរាប់ប្រព័ន្ធតាមដានពតិមានបទល្មើសព្រៃឈើ
- កម្មសិក្សានៅសាលាដំបូងខេត្ត

**២-១ នីតិវិធីសមស្របសំរាប់ការឃាត់ខ្លួន ឆែកឆេរ ស៊ើបអង្កេត ការប្រមូល និងរក្សាទុកវត្ថុតាងបទល្មើស (តំរូវការដីកា ការចាប់ឃាត់វត្ថុតាងនិងការចងក្រងសំណុំរឿងបទល្មើស បណ្តាញស៊ើបអង្កេត ការរៀបចំផែនការទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើ)**

ច្បាប់ស្តីពីព្រៃឈើ និង ក្រមនីតិវិធីព្រហ្មទណ្ឌមានវិធានសំរាប់ធ្វើការឆែកឆេរ។ គ្រូបណ្តុះបណ្តាលនឹងផ្តល់ពតិមានដល់សិក្ខាកាមអំពី :

**២-១-១ ការឃាត់ខ្លួន**

- ការឃាត់ខ្លួនក្នុងករណីបទល្មើសជាក់ស្តែង
- ការឃាត់ខ្លួនតាមការបង្គាប់របស់តុលាការ

**២-១-២ ការឆែកឆេរលំនៅដ្ឋាន**

- សិទ្ធិក្នុងការឆែកឆេររបស់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌
- នីតិវិធី និង ពេលវេលាកំណត់ក្នុងការឆែកឆេរ

**២-១-៣ ដំណាក់ការនៃការថែរក្សាវត្ថុតាង**

- សុវត្ថិភាពកន្លែងកើតហេតុ
- ចងក្រងឯកសារកន្លែងកើតហេតុ
- ថតរូបភាព ឬ វីដេអូកន្លែងកើតហេតុ
- ប្រមូលវត្ថុតាងបទល្មើស
- ការបិទស្លាកបោះត្រាលើវត្ថុតាងបទល្មើស
- ថែរក្សាវត្ថុតាង

**២-១-៤ ការសំភាសន៍ជនសង្ស័យ និង សាក្សី**

- ការសំភាសន៍ជនសង្ស័យ
- ការសំភាសន៍សាក្សី

**២-១-៥ បណ្តាញស៊ើបអង្កេត**

- ការបង្កើតបណ្តាញស៊ើបអង្កេត
- ការសហការឱ្យមានប្រសិទ្ធភាពជាមួយសហគមន៍ និង អាជ្ញាធរមូលដ្ឋាន
- ការផ្តល់ការលើកទឹកចិត្តដល់អ្នកផ្តល់ពតិមាន

**២-១-៦ ការរៀបចំផែនការការងារទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើ**

- ផែនការទប់ស្កាត់បទល្មើសព្រៃឈើគួរបញ្ចូលការងារដូចខាងក្រោម :

  ១- រៀបចំផែនការសកម្មភាពផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ និង លិខិតបទដ្ឋានគតិយុត្តដល់អ្នកពាក់ព័ន្ធនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមរយៈការចែកឯកសារ ការប្រជុំ និង កម្មវិធីផ្សេងៗ

ពិសេសការផ្សព្វផ្សាយពាក់ព័ន្ធនឹងបទល្មើសកាប់រានដីព្រៃខុសច្បាប់។ ការផ្សព្វផ្សាយគួរធ្វើឱ្យបានរហូតដល់ភូមិ

២- ធ្វើការល្បាតត្រួតពិនិត្យបទល្មើសព្រៃឈើជាប្រចាំនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ពិសេសតាមបណ្ដោយផ្លូវ ក្នុងព្រៃ ដេប៉ូ និង រោងអារឈើ ដើម្បីរកបទល្មើសព្រៃឈើ និង ដើម្បីធ្វើឱ្យជនល្មើសមានការភ័យខ្លាច

៣- បង្កើត និង លើកទឹកចិត្តអ្នកផ្ដល់ពត៌មានបទល្មើសព្រៃឈើ និង ផ្ដល់សុវត្ថភាពសំរាប់ពួកគេ។

- ផែនការបង្ក្រាបបទល្មើសព្រៃឈើគួរបញ្ចូលការងារដូចខាងក្រោម :

១- ការទទួលពត៌មានបទល្មើសព្រៃឈើពីប្រភព និង អ្នកផ្ដល់ពត៌មាន

២- ចុះពិនិត្យ និង ផ្ទៀងផ្ទាត់ពត៌មានបទល្មើសព្រៃឈើដែលបានទទួល ហើយចាត់វិធានការតាមនីតិវិធីដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ និង អនុគណៈកម្មាធិការខេត្ត និង/ឬ ក្រុមការងារថ្នាក់ស្រុក

៣- ចងក្រងឯកសារ និង រៀបចំរបាយការណ៍ជូនថ្នាក់លើរបស់ខ្លួនជ្រាប និង ស្នើសុំការសំរេចក្នុងករណីមិនប្រក្រតី។

## ២-២ ឯកសារដែលត្រូវការសំរាប់ចងក្រងសំណុំរឿងទៅតុលាការ

គ្រូបណ្ដុះបណ្ដាលនឹងធ្វើការបង្ហាញដល់សិក្ខាកាមអំពី ទំរង់លិខិតដែលត្រូវបំពេញដោយមន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ( ប្រកាសរួមលេខ ០៩៧ ប្រក.កសក-កយ/០៦ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងយុត្តិធម៌ ស្ដីពីទំរង់បែបបទនៃកំណត់ហេតុបទល្មើសព្រៃឈើ។ ទំរង់លិខិតទាំងនេះគឺ :

- កំណត់ហេតុនៃបទល្មើស
- កំណត់ហេតុបទល្មើសជាក់ស្ដែង
- កំណត់ហេតុឆែកឆេរ
- កំណត់ហេតុសួរចម្លើយ
- កំណត់ហេតុដកហូត ឃាត់ទុកវត្ថុតាងបណ្ដោះអាសន្ន
- កំណត់ហេតុយកគំរូសំណាកផល អនុផលព្រៃឈើមកវិភាគ
- កំណត់ហេតុឃាត់ខ្លួនបណ្ដោះអាសន្ន
- កំណត់ហេតុប្រគល់ ទទួលជនល្មើសដែលបានឃាត់ខ្លួន
- ព្រឹត្តិប័ត្រព័ត៌មាន
- សលាកប័ត្រទោសទណ្ឌ

- លិខិតទទួលថែរក្សាវត្ថុតាង
- សេចក្តីសម្រេចស្តីពីការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ
- ដីកាអម

លិខិតសំខាន់ៗសំរាប់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ត្រូវរៀបចំះ

- លិខិតស្នើសុំដីកាឆែកឆេរ
- លិខិតស្នើសុំដីកាឃាត់ខ្លួន
- លិខិតសារភាពទោសកំហុស និងស្នើសុំពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ ។

## ២-៣ ទំរង់របាយការណ៍ស៊ើបអង្កេតដំបូងលើបទល្មើសព្រៃឈើ

ក្រៅពីទំរង់បែបបទដែលត្រូវបំពេញដើម្បីចងក្រងសំណុំរឿងទៅតុលាការ ឬ លិខិតសារភាពទោសកំហុស និងស្នើសុំពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ មានទំរង់លិខិតផ្សេងទៀតត្រូវការបំពេញដោយមន្ត្រីរដ្ឋបាលព្រៃឈើដែលទទួលការងារនេះ ។ នេះគឺជាទំរង់លិខិតផ្ទៃក្នុងសំរាប់ប្រើប្រាស់ដោយរដ្ឋបាលព្រៃឈើ និង ត្រូវការដើម្បីបញ្ចូលទិន្នន័យក្នុងប្រព័ន្ធតាមដានពត៌មានបទល្មើសព្រៃឈើរបស់ផ្នែកតាមដាន និង រាយការណ៍ពីឧក្រិដ្ឋកម្មព្រៃឈើ ។ ប្រព័ន្ធតាមដាននេះគឺមានសារសំខាន់ណាស់ក្នុងការតាមដានពត៌មានបទល្មើសព្រៃឈើទូទាំងប្រទេស និងសំរាប់កំណត់បទល្មើស និង/ឬ ជនល្មើស ។ វាគឺជាឧបករណ៍ពង្រឹងការអនុវត្តច្បាប់មួយដែលអាចកំណត់ជនល្មើសដែលធ្លាប់បានប្រព្រឹត្តបទល្មើសកន្លងមក ការប្រព្រឹត្ត និង ទំហំនៃការប្រព្រឹត្តបទល្មើស ។

គ្រូបណ្តុះបណ្តាលនឹងធ្វើការបង្ហាញដល់សិក្ខាកាមអំពី :

- វិធីនៃការបំពេញគំរូរបាយការណ៍ស៊ើបអង្កេតដំបូងអំពីបទល្មើសព្រៃឈើ និង ទីកន្លែងដែលគួរផ្ញើទៅ
- លេខកូដរាជធានី និង ខេត្ត
- ការចាត់ថ្នាក់ប្រភេទបទល្មើស និង អនុប្រភេទបទល្មើស (C, T, W, P, E, I and M)
- ការចាត់ថ្នាក់ចំណាត់ការនៃបទល្មើស (A, J and C)

## ២-៤ លំហាត់អនុវត្ត

គ្រូបណ្តុះបណ្តាលនឹងផ្តល់ដល់សិក្ខាកាមនូវលំហាត់អនុវត្តស្តីពីមុខវិជ្ជាដូចខាងក្រោម :

- ករណីការកាប់រានដីព្រៃខុសច្បាប់
- ករណីការកាប់ឈើខុសច្បាប់
- ករណីការធ្វើពាណិជ្ជកម្មសត្វព្រៃខុសច្បាប់
- ការរៀបចំផែនការប្រតិបត្តិការបង្ក្រាបបទល្មើសព្រៃឈើ
- សកម្មភាពសហគមន៍ព្រៃឈើ
- លំហាត់អនុវត្តនឹងធ្វើការពិភាក្សាក្នុងក្រុមដើម្បីកំណត់បញ្ហា និងរកវិធីដោះស្រាយបញ្ហាទាំងនេះ ។

## ម៉ូឌុល៣៖ ច្បាប់សំខាន់ៗ និង ប្រព័ន្ធតុលាការនៅកម្ពុជា (៤ថ្ងៃ : ៣.៥ ថ្ងៃ សិក្សាក្នុងថ្នាក់)

**មុខវិជ្ជាដែលត្រូវបណ្តុះបណ្តាលរួមមាន :**

១- ច្បាប់ស្តីពីព្រៃឈើ (ផ្តោតលើជំពូក ១៤-១៧)

២- ច្បាប់ភូមិបាល (ផ្តោតលើប្រភេទដី និង ទោសប្បញ្ញត្តិចំពោះការកាប់រានដីព្រៃឈើ)

៣- ក្រមនីតិវិធីព្រហ្មទណ្ឌ (ផ្តោតលើតួនាទីក្នុងការពង្រឹងការអនុវត្តច្បាប់ សេចក្តីសង្ខេបប្រព័ន្ធតុលាការ និង នីតិវិធីពាក់ព័ន្ធនឹងតុលាការ)

៤- ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (មាត្រាស្តីពីការពង្រឹងការអនុវត្តច្បាប់)

៥- ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងច្បាប់ស្តីពីព្រៃឈើ

### គោលដៅនៃវគ្គ/គោលបំណងនៃការសិក្សា

- ដើម្បីសិក្សាអំពីច្បាប់សំខាន់ៗ និង លិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលចាំបាច់សំរាប់ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ
- ដើម្បីយល់ដឹងអំពីប្រព័ន្ធតុលាការនៅកម្ពុជា

### គោលបំណងសំរេចបាន

នៅចុងបញ្ចប់នៃវគ្គនេះសិក្ខាកាមនឹងទទួលបាននូវៈ

- ការពន្យល់អំពីប្បញ្ញត្តិសំខាន់ៗនៃច្បាប់ និង លិខិតបទដ្ឋានគតិយុត្តផ្សេងៗ
- ការយល់ដឹងថាតើហេតុអ្វីបានជាច្បាប់ទាំងនេះមានសារៈសំខាន់ចំពោះការពង្រឹងការអនុវត្តច្បាប់
- ការយល់ដឹងថាតើច្បាប់មានទំនាក់ទំនងជាមួយច្បាប់ផ្សេងៗទៀតយ៉ាងណា
- ការពិពណ៌នាអំពីប្រព័ន្ធតុលាការ និង ដំណើរការរបស់តុលាការ

### វិធីសាស្ត្រនៃការបណ្តុះបណ្តាល

វិធីសាស្ត្រក្នុងការបណ្តុះបណ្តាលរួមមានការឧទ្ទេសនាម ឯកសារមេរៀន សំណួរនិងចម្លើយ ឧទាហរណ៍ និង ការពន្យល់។

### សំភារៈ និង ឧបករណ៍អនុវត្ត

- ថ្នាក់រៀន
- ក្តារខៀន
- កុំព្យូទ័រយួរដៃ និង ឧបករណ៍បញ្ចាំងស្លាយ
- ច្បាប់សំខាន់ៗ និង អនុក្រឹត្យ

- ក្រាហ្វិក/សេចក្តីសង្ខេបនៃប្រព័ន្ធតុលាការនៅកម្ពុជា
- តារាងម៉ាទ្រីកនៃបទល្មើសពាក់ព័ន្ធនឹងការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ

**ការវាយតំលៃ**

- វគ្គសំណួរ និង ចម្លើយលើចំណុចសំខាន់ៗដែលបានកើតឡើង
- លំហាត់អនុវត្ត ការដើរតួសំដែង និង ការពិភាក្សាក្រុម
- ការចោទសួរថាតើត្រូវរកពតិមានតាមផ្លូវច្បាប់នៅកន្លែងណានៅពេលកន្លងមក ។

### ៣-១ ច្បាប់ស្តីពីព្រៃឈើ ( ជំពូក ១៤-១៧ )

ច្បាប់នេះកំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការអភិវឌ្ឍន៍ និង ការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គោលបំណងនៃច្បាប់នេះគឺធានានូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវៈចំរុះ និង មរតកវប្បធម៌។

គ្រូបណ្តុះបណ្តាលនឹងធ្វើការបង្ហាញចំណុចសំខាន់ៗដូចមានប្បញ្ញត្តិក្នុងជំពូកទី ១៤-១៧ នៃច្បាប់ស្តីពីព្រៃឈើដល់សិក្ខាកាមដូចខាងក្រោម :

### ៣-១-១ ជំពូកទី១៤ : នីតិវិធីដោះស្រាយបទល្មើសព្រៃឈើ

- តួនាទី និង ភារៈកិច្ចរបស់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និង មន្ត្រីរដ្ឋបាលព្រៃឈើក្នុងការស៊ើបអង្កេត ត្រួតពិនិត្យ បង្ក្រាប និង ចងក្រងសំណុំរឿងបទល្មើសព្រៃនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- តួនាទី និង ភារៈកិច្ចរបស់អាជ្ញាធរមូលដ្ឋាន កងកំលាំងប្រដាប់អាវុធ និង អង្គភាពផ្សេងៗក្នុងការសំរបសំរួល និង ជួយរដ្ឋបាលព្រៃឈើលើការស៊ើបអង្កេត ការទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើ
- សិទ្ធិអំណាចរបស់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងការបំពេញភារៈកិច្ចរបស់ពួកគេ
- ការរៀបចំសំណុំឯកសារបទល្មើសព្រៃឈើ និង គំរូលិខិតសំរាប់ការធ្វើកំណត់ហេតុបទល្មើសព្រៃឈើ
- វត្ថុតាងបទល្មើសព្រៃឈើ និង ការដោះស្រាយវត្ថុតាង
- អាជ្ញាយុកាលនៃបណ្តឹងបទល្មើសព្រៃឈើទៅតុលាការ
- សិទ្ធិរបស់បុគ្គលម្នាក់ៗក្នុងការប្តឹងតវ៉ាទៅប្រធានរដ្ឋបាលព្រៃឈើ និង ការសំរេចរបស់ប្រធានរដ្ឋបាលព្រៃឈើ។

### ៣-១-២ ជំពូកទី១៥ :នីតិវិធីដោះស្រាយបទល្មើសព្រៃឈើ

- ទណ្ឌកម្មនៃបទល្មើសព្រៃឈើ
- វិធាន និង សិទ្ធិក្នុងការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ
- សិទ្ធិអំណាចរបស់រដ្ឋបាលព្រៃឈើ និង តុលាការក្នុងការដោះស្រាយបទល្មើសព្រៃឈើ
- ការគំរាមកំហែង និង ការរាំងស្ទះរបស់មន្ត្រីអាជ្ញាធរមូលដ្ឋាន និង អង្គភាពផ្សេងៗចំពោះប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើ
- បទល្មើសព្រៃឈើប្រព្រឹត្តដោយមន្ត្រីរដ្ឋបាលព្រៃឈើ និង ទោសទណ្ឌ។

### ៣-១-៣ ជំពូកទី ១៦ : ការអនុវត្តសាលក្រមតុលាការ

- ការអនុវត្តសាលក្រម ឬសាលដីកាស្ថាពរនៃបទល្មើសព្រៃឈើ
- ការថតចំលងសាលក្រម ឬសាលដីកានៃបទល្មើសព្រៃឈើជូនរដ្ឋបាលព្រៃឈើ
- ការចាត់ចែងវត្ថុតាងបទល្មើសដែលបានរឹបអូសបន្ទាប់ពីសាលក្រម ឬសាលដីកាស្ថាពរ ។

### ៣-១-៤ ជំពូកទី ១៧ : អន្តរប្បញ្ញត្តិ

- សិទ្ធិអំណាចរបស់រដ្ឋបាលព្រៃឈើក្នុងការបណ្តេញ និង ទាមទារកម្មសិទ្ធិនៃដីព្រៃមកជាសម្បត្តិរដ្ឋវិញ
- ការផ្ទេរសមត្ថកិច្ចក្នុងការគ្រប់គ្រងរោងចក្រ និង រោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល មកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

## ៣-២ ច្បាប់ភូមិបាល ( មាត្រា ១៥, ១៦, ១៧, ១៨, ១៩, ២៩, ៣១, ៤៣, ៤៤, ២៥៩)

ច្បាប់នេះកំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការអភិវឌ្ឍន៍ និង ការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

គ្រូបណ្តុះបណ្តាលនឹងធ្វើការបង្ហាញមាត្រាសំខាន់ៗនៃច្បាប់ភូមិបាលឆ្នាំ ២០០១ ដល់សិក្ខាកាមដើម្បីយល់ដឹងអំពីការពាក់ព័ន្ធនៃច្បាប់នេះជាមួយច្បាប់ស្តីពីព្រៃឈើៈ

- សម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- ការហាមឃាត់លក់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ
- សម្បត្តិឯកជនរបស់រដ្ឋ និង របស់នីតិបុគ្គលឯកជនសាធារណៈ
- មោឃៈភាពក្នុងការកាន់កាប់សម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- គ្មានលទ្ធកម្មសម្បត្តិសាធារណៈរបស់រដ្ឋ
- មោឃៈភាពឯកសារទាក់ទងនឹងការកាន់កាប់សម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈរបស់រដ្ឋ
- ការផ្តន្ទាទោសចំពោះការកាប់រានដីសាធារណៈរបស់រដ្ឋ និង ដីឯកជនរបស់រដ្ឋ ។

## ៣-៣ ក្រមនីតិវិធីព្រហ្មទណ្ឌ

ក្រមនីតិវិធីព្រហ្មទណ្ឌបានបង្កើតនូវនីតិវិធីក្នុងការនាំយកករណីបទល្មើសទៅតុលាការ និង ដំណើរការដោយតុលាការ ។

គ្រូបណ្តុះបណ្តាលនឹងធ្វើការបង្ហាញដល់សិក្ខាកាមអំពី :

### ៣-៣-១ ប្រព័ន្ធតុលាការនៅកម្ពុជា

- សាលាដំបូងរាជធានី ខេត្ត
- សាលាឧទ្ធរណ៍

- តុលាការកំពូល

**៣-៣-២ អង្គការអយ្យការ**

- តួនាទីរបស់អង្គការអយ្យការ
- ចៅក្រមអយ្យការ
- ឋានានុក្រមនៃអង្គការអយ្យការ
- មុខការរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- មុខការរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- មុខការរបស់ព្រះរាជអាជ្ញាអមសាលាដំបូង
- អំណាចរបស់ព្រះរាជអាជ្ញា និង ព្រះរាជអាជ្ញារង
- ការតម្កល់រឿងទុកឥតចាត់ការ

**៣-៣-៣ ចៅក្រមស៊ើបសួរ និង សភាស៊ើបសួរ**

- ការចាត់តាំងដោយប្រធានតុលាការ
- ការបែងចែកសំណុំរឿងដោយប្រធានតុលាការ
- ការដកហូតសំណុំរឿងពីចៅក្រមស៊ើបសួរ
- សភាពិសេសនៃសាលាឧទ្ធរណ៍

**៣-៣-៤ នគរបាលយុត្តិធម៌**

- បេសកកម្មរបស់នគរបាលយុត្តិធម៌
- សមាសភាពរបស់នគរបាលយុត្តិធម៌
- ការសំរបសំរួលសកម្មភាពការងាររបស់នគរបាលយុត្តិធម៌
- ការត្រួតពិនិត្យលើនគរបាលយុត្តិធម៌

**៣-៣-៥ មន្ត្រីនគរបាលយុត្តិធម៌**

- ការទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌
- មន្ត្រីនគរបាលយុត្តិធម៌
- នីតិវិធីខាងវិន័យ
- ទណ្ឌកម្មខាងវិន័យ
- ការហាមឃាត់មិនឱ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌
- សមត្ថកិច្ចដែនដីរបស់មន្ត្រីនគរបាលយុត្តិធម៌
- បេសកកម្មនៃមន្ត្រីនគរបាលយុត្តិធម៌

**៣-៣-៦ ភ្នាក់ងារនគរបាលយុត្តិធមិ**

- ការទទួលបាននូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធមិ
- សម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធមិ
- បេសកកម្មនៃភ្នាក់ងារនគរបាលយុត្តិធមិ
- កំហុសដែលត្រូវបានប្រព្រឹត្តនៅក្នុងពេលបំពេញមុខងារ
- ទណ្ឌកម្មខាងវិន័យ
- ការផ្តល់នីតិសម្បទាចំពោះមន្ត្រីរាជការ និង ភ្នាក់ងារសាធារណៈដទៃទៀត

**៣-៣-៧ សាលក្រម និង ការប្តឹងឧទ្ធរណ៍**

- សាលក្រមសាលាដំបូង
- ប្រភេទនៃសាលក្រម
- បណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ និង រយៈពេលសំរាប់ធ្វើបណ្តឹងទាស់
- បណ្តឹងឧទ្ធរណ៍ និង រយៈពេលសំរាប់ធ្វើបណ្តឹងឧទ្ធរណ៍
- ប្រភេទនៃសាលដីកា
- បណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខ និង រយៈពេលសំរាប់ធ្វើបណ្តឹងទាស់
- បណ្តឹងសាទុក្ខ និង រយៈពេលសំរាប់ធ្វើបណ្តឹងសាទុក្ខ
- រយៈពេលសំរាប់សរសេរសារណា
- បណ្តឹងសើរើរឿងក្តី

## ៣-៤ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ (ជំពូកទី ១០ : មាត្រា ៥៣-៦៤)

ច្បាប់នេះបានអនុម័តនៅឆ្នាំ ២០០៨ កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការអភិរក្ស និង ការអភិវឌ្ឍតំបន់ការពារធម្មជាតិ។ គោលបំណងនៃច្បាប់នេះគឺធានានូវការគ្រប់គ្រង ការអភិរក្សជីវៈចំរុះ និង ការធានាប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាព។ ក្រសួងបរិស្ថានទទួលខុសត្រូវក្នុងការអនុវត្តច្បាប់នេះ។

ជំពូកទី ១០ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិបានកំណត់ថាតើប្រភេទបទល្មើសដែលត្រូវផ្តន្ទាទោសជាប់ពន្ធនាគារ និងប្រភេទបទល្មើសអ្វីខ្លះដែលត្រូវធ្វើការពិន័យ។ ក្រៅពីទណ្ឌកម្មទាំងនេះវត្ថុតាងទាំងអស់ត្រូវរឹបអូស។

គ្រូបណ្តុះបណ្តាលនឹងធ្វើការបង្ហាញសិក្ខាកាមអំពី :

- ប្រភេទផ្សេងៗនៃទណ្ឌកម្ម
- ដំណើរការលក់វត្ថុតាងដោយតុលាការ
- ការកំណត់ជាក់លាក់នៃការដាក់ទណ្ឌកម្ម

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការពិន័យអន្តរការណ៍
- បទល្មើសថ្នាក់ទី ២ ទី៣ និង ទី៤
- ទណ្ឌកម្មដោយសារការរាំងស្ទះប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលការពារ និង អភិរក្សធម្មជាតិ
- ទណ្ឌកម្មចំពោះមន្ត្រីរដ្ឋបាលការពារ និង អភិរក្សធម្មជាតិដែលធ្វេសប្រហែស ឬ ប្រព្រឹត្តខុសច្បាប់។

## ៣-៥ ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តផ្សេងៗ

គ្រូបណ្តុះបណ្តាលនឹងធ្វើការបង្ហាញសិក្ខាកាមអំពីច្បាប់ពាក់ព័ន្ធផ្សេងៗ អនុក្រឹត្យ និង បទបញ្ជាដែលទាក់ទងនឹងការវិនិយោគដីព្រៃ ការបែងចែងដីព្រៃដល់ប្រជាពលរដ្ឋដែលគ្មានដី និង នីតិវិធីដើម្បីទប់ស្កាត់ ដកហូត និង ដោះស្រាយការកាប់រាន និង ហ៊ុមព័ទ្ធវាតយកដីព្រៃឈើជាកម្មសិទ្ធិ។ ច្បាប់ និង លិខិតបទដ្ឋានគតិយុត្តទាំងនេះគឺ :

- ច្បាប់ស្តីពីការគ្រប់គ្រងធនធានរ៉ែ និង ការធ្វើអាជីវកម្ម (មាត្រា ២-៣, ៧-៨, ២១, ៣៣-៣៥, ៣៨)។
- ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក (មាត្រា ៥, ១០, ១២, ២២ និង ៣៦)។
- ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវ (ជំពូកទី ២ : មាត្រា ៤-១៧, ជំពូកទី ៤: មាត្រា ១៩-២៤)។
- អនុក្រឹត្យលេខ ១៥៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីនីតិវិធី និង លក្ខខណ្ឌការគ្រប់គ្រង ការប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវរបស់កងយុទ្ធពលខេមរភូមិន្ទ កងកំលាំងនគរបាលជាតិ ស្ថាប័នសាធារណៈ និង មន្ត្រី។
- គោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីការប្រើប្រាស់កំលាំង និង អាវុធ ដោយមន្ត្រីអនុវត្តច្បាប់ ដែលគោលការណ៍នេះបានផ្តល់ពតិមានអំពីស្ថានភាពនៅពេលដែលមន្ត្រីអនុវត្តច្បាប់អាចផ្ទុះអាវុធបាន។
- អនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច។ អនុក្រឹត្យនេះមានគោលដៅកំណត់លក្ខណៈវិនិច្ឆ័យ នីតិវិធី យន្តការ និង ការរៀបចំស្ថាប័នសំរាប់ការផ្តួចផ្តើម និង ការផ្តល់សម្បទានដីសេដ្ឋកិច្ច សំរាប់ការតាមដានត្រួតពិនិត្យការអនុវត្តកិច្ចសន្យា និង សំរាប់ការត្រួតពិនិត្យឡើងវិញលើសម្បទានដីសេដ្ឋកិច្ចដែលបានចុះកិច្ចសន្យាមុនពេលដែលអនុក្រឹត្យនេះចូលជាធរមាន ស្របតាមការកំណត់នៃច្បាប់ភូមិបាលឆ្នាំ ២០០១។
- អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច។ អនុក្រឹត្យនេះកំណត់នីតិវិធី លក្ខណៈវិនិច្ឆ័យ និង យន្តការសំរាប់ធ្វើការផ្តល់សម្បទានដីសង្គមកិច្ចដើម្បីសង់លំនៅឋាន ឬ/នឹងដើម្បីធ្វើកសិកម្មជាលក្ខណៈគ្រួសារ។

- បទបញ្ជាលេខ ០១ បប ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៤ របស់រាជរដ្ឋាភិបាល ស្តីពីការទប់ស្កាត់ បង្ក្រាប និង លុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និងការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ។ បទបញ្ជានេះបានដាក់ចេញនូវវិធានការទប់ស្កាត់ និង បង្ក្រាបការកាប់រាន និង ហ៊ុមព័ទ្ធដីព្រៃឈើវាត យកធ្វើជាកម្មសិទ្ធិខុសច្បាប់។
- បទបញ្ជាលេខ ០១ បប ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការទប់ស្កាត់ ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិ។ បទបញ្ជានេះបានកំណត់ថា ដីព្រៃឈើ គ្រប់ប្រភេទដែលបានកាប់រាន និង ហ៊ុមព័ទ្ធខុសច្បាប់ ត្រូវដកហូតមកជាសម្បត្តិរដ្ឋវិញ។
- បទបញ្ជាលេខ ០២ បប ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រង និងត្រួតពិនិត្យលើការប្រើប្រាស់រណាយន្តកាត់-អារឈើ ។ បទបញ្ជានេះគឺដើម្បីទប់ស្កាត់ការប្រើ ប្រាស់រណាយន្តអារឈើគ្មានការអនុញ្ញាត និង ដើម្បីដកហូតរណារយន្តអារឈើខុសច្បាប់។
- សារាចរលេខ ០២ សរ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាល ស្តីពីការកាន់កាប់ដី រដ្ឋដោយខុសច្បាប់។ សារាចរនេះបានកំណត់នីតិវិធីសំរាប់ដកហូតដីព្រៃឈើគ្រប់ប្រភេទតាមបទ បញ្ជាលេខ ០១ បប ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការទប់ស្កាត់ការ កាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិ។
- សុន្ទរកថារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឆ្នាំ ២០០៨-២០០៩ និង ទិសដៅឆ្នាំ ២០១០។ សុន្ទរកថានេះបានលើកឡើងអំពីការពង្រឹងឱ្យមានប្រសិទ្ធភាពការអនុវត្តច្បាប់ ស្តីពីព្រៃឈើ បទបញ្ជា និង លិខិតបទដ្ឋានគតិយុត្ត ដើម្បីទប់ស្កាត់ និង លុបបំបាត់ភាពអនាធិប តេយ្យគ្រប់ប្រភេទ និងស្នើឱ្យតុលាការចាត់ការឱ្យបានឆាប់រហ័សនូវសំណុំរឿងបទល្មើសព្រៃឈើដែល បានបញ្ជូនទៅតុលាការ។

## ម៉ូឌុល ៤ : ជំនាញពិសេស (២ថ្ងៃ : ១,៥ ថ្ងៃសិក្សាក្នុងថ្នាក់ និង កន្លះថ្ងៃកម្មសិក្សាទីវាល)

**មុខវិជ្ជាដែលត្រូវបណ្តុះបណ្តាលរួមមាន :**

១- ជំនាញទំនាក់ទំនង និង ការចរចារ

២- ការគ្រប់គ្រង និង ដោះស្រាយទំនាស់

៣- ការប្រើប្រាស់ GPS និង ផែនទី

៤- ការគ្រប់គ្រង និង ចងក្រងឯកសារ

**គោលដៅនៃវគ្គ/គោលបំណងនៃការសិក្សា**

- ដើម្បីយល់ដឹង ថាតើធ្វើយ៉ាងណាដើម្បីឱ្យអ្នកពាក់ព័ន្ធផ្សេងៗចូលរួមការអនុវត្តច្បាប់ស្តីពីព្រៃឈើ
- ដើម្បីយល់ដឹង ថាតើត្រូវដោះស្រាយទំនាស់តូចតាចបែបណាដោយសន្តិវិធី
- ដើម្បីយល់ដឹងអំពីការប្រើប្រាស់ GPS និង ផែនទី
- ដើម្បីយល់ដឹងអំពីរបៀបបង្កើត និង គ្រប់គ្រងឯកសារ

**គោលបំណងសំរេចបាន**

នៅចុងបញ្ចប់នៃវគ្គនេះសិក្ខាកាមនឹងទទួលបាននូវៈ

- ការសន្ទនា និង កិច្ចសហប្រតិបត្តិការល្អជាមួយព្រះរាជអាជ្ញា ចៅក្រម និង មន្ត្រីអនុវត្តច្បាប់ផ្សេងៗទៀតនៃអង្គភាពពាក់ព័ន្ធ និង សហគមន៍
- ការដោះស្រាយទំនាស់តូចតាចដោយសន្តិវិធី
- ការយល់ដឹងអំពីការប្រើប្រាស់ចំណុចនិយាមកានៃGPS និងការដាក់បញ្ចូលចំណុចនិយាមកាលើផែនទី
- ការយល់ដឹងអំពីការរៀបចំ និង ការចងក្រងឯកសារពាក់ព័ន្ធនឹងសំណុំរឿងបទល្មើសព្រៃឈើ និង សកម្មភាពអនុវត្តច្បាប់ផ្សេងៗទៀត ។

**វិធីសាស្ត្រនៃការបណ្តុះបណ្តាល**

វិធីសាស្ត្រក្នុងការបណ្តុះបណ្តាលរួមមានការឧទ្ទេសនាម ឯកសារមេរៀន សំណួរនិងចម្លើយ ឧទាហរណ៍ និង ការពន្យល់ ។

**សំភារៈ និង ឧបករណ៍អនុវត្ត**

- ថ្នាក់រៀន
- ក្តារខៀន
- កុំព្យូទ័រយួរដៃ និង ឧបករណ៍បញ្ចាំងស្លាយ

**ការវាយតំលៃ**

- វគ្គសំណួរ និង ចម្លើយលើចំណុចសំខាន់ៗដែលបានកើតឡើង
- ការដើរតួសំដែងក្នុងការសន្ទនាជាមួយសហគមន៍ និង ជាមួយមន្ត្រីតុលាការ
- លំហាត់អំពីវិធីប្រើប្រាស់ GPS ឬផែនទីនៅឧទ្យានសួនសត្វ និង មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ
- លំហាត់អំពីវិធីទុកដាក់ និង រកឯកសារ ។

### ៤-១ ជំនាញទំនាក់ទំនង និង ការចរចារ

#### ៤-១-១ ជំនាញទំនាក់ទំនង

ការទំនាក់ទំនងប្រកបដោយជោគជ័យគឺ អាស្រ័យលើការបញ្ជូនសាររបស់អ្នកទៅកាន់អ្នកផ្សេងៗយ៉ាងច្បាស់ និងមានន័យច្បាស់លាស់។ វាក៏អាស្រ័យផងដែរលើការទទួលពត៌មានពីអ្នកផ្សេងដែលបានផ្ញើមកអ្នក ហើយមានការខុសគ្នាតិចតួចពីភាពដើមបើអាចធ្វើទៅបាន។ គ្រូបណ្តុះបណ្តាលនឹងផ្តល់ពត៌មានអំពី :

- ដំណើរការបញ្ជូនពត៌មាន និងការយល់ដឹងពីមនុស្សម្នាក់ទៅមនុស្សផ្សេងទៀត និងឧបសគ្គបីយ៉ាងក្នុងការទំនាក់ទំនងគឺ លក្ខណៈរូប ភាសា និង លក្ខណៈផ្ទាល់ខ្លួន (physical, semantic and personal)
- ដំណើរការទំនាក់ទំនង : អ្វីជាការទំនាក់ទំនង និង តើការទំនាក់ទំនងដោយវិធីណា?
- ឧបសគ្គចំពោះការទំនាក់ទំនង
- តើអ្នកគ្រប់គ្រងរៀបចំដំណើរការទំនាក់ទំនងយ៉ាងដូចម្តេច ?
- ការទំនាក់ទំនងអាស្រ័យលើអាយុអ្នកផ្តល់ពត៌មាន
- ការធ្វើឱ្យប្រសើរការងារទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។

#### ៤-១-២ ជំនាញចរចារ

ជំនាញចរចារមានសារៈសំខាន់សំរាប់មន្ត្រីរដ្ឋបាលព្រៃឈើដែលត្រូវធ្វើជាមួយសហគមន៍ មន្ត្រីអនុវត្តច្បាប់ផ្សេងៗ និង អាជ្ញាធរមូលដ្ឋាន។ គ្រូបណ្តុះបណ្តាលនឹងបង្រៀនសិក្ខាកាមអំពី :

- តើការចរចារធ្វើនៅពេលណា និង តាមវិធីណាដោយរួមបញ្ចូលនូវមធ្យោបាយខុសៗគ្នាដើម្បីសំរេចគោលបំណងរបស់អ្នក
- តើធ្វើយ៉ាងណាដើម្បីសំរេចបានស្ថានភាពឈ្នះ-ឈ្នះ។

### ៤-២ ការគ្រប់គ្រង និង ដោះស្រាយទំនាស់

គ្រូបណ្តុះបណ្តាលនឹងធ្វើបទបង្ហាញដល់សិក្ខាកាមអំពីការគ្រប់គ្រងទំនាស់ និង គោលនយោបាយ :

- ការពិពណ៌នាអំពីទំនាស់
- ធាតុផ្សំនៃទំនាស់
- ទំហំនៃទំនាស់
- ការគ្រប់គ្រងបញ្ហា
- មូលហេតុនៃទំនាស់
- ប្រតិកម្មចំពោះទំនាស់
- ការឆ្លើយតបចំពោះទំនាស់
- ការគ្រប់គ្រងទំនាស់
- ការគ្រប់គ្រងទំនាស់ដោយជោគជ័យ

## ៤-៣ ការប្រើប្រាស់ GPS និង មើលផែនទី

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ត្រូវការដឹងអំពីវិធីប្រើប្រាស់ និង មើលផែនទីនៅពេលដែលពួកគេមានផែនការចុះប្រតិបត្តិការ និង ធ្វើការល្បាតត្រួតពិនិតនៅក្នុងព្រៃ។ ពេលខ្លះប្រព័ន្ធ GPS មិនដំណើរការនៅក្នុងគំរបព្រៃក្រាស់ ឬ អាកាសធាតុមិនល្អ។ ការយល់ដឹងនូវរបៀបមើលផែនទីនឹងជួយមន្ត្រីរដ្ឋបាលព្រៃឈើស្គាល់ទីតាំងដែលពួកគេចុះប្រតិបត្តិការ និង ទីកន្លែងដែលពួគគេត្រូវទៅ។

គ្រូបណ្តុះបណ្តាលនឹងធ្វើបទបង្ហាញដល់សិក្ខាកាមអំពីៈ

### ៤-៣-១ ការប្រើប្រាស់ GPS

- អ្វីជាឧបករណ៍ GPS?
- តើគេប្រើប្រាស់ GPS ដើម្បីអ្វី?
- ការកំណត់ទីតាំង
- របៀបកត់ត្រាចំណុចនិយាមកា (UTM) នៃទីតាំងក្នុង GPS
- របៀបរកចំណុចនិយាមកា (UTM) នៃទីតាំងដែលបានកត់ត្រាទុកក្នុង GPS
- របៀបរកទីតាំងនៅទីវាលជាក់ស្តែង
- របៀបលុបចោលចំណុចគោលដៅត្រូវរក (Waypoint) ក្នុង GPS

### ៤-៣-២ ការមើលផែនទី

- អ្វីជាផែនទី?
- លក្ខណៈនៃផែនទី
- ហេតុអ្វីចាំបាច់ត្រូវដឹងរបៀបមើលផែនទី?
- ប្រភេទនៃផែនទី
- ផែនទីឋានលេខា
- របៀបគណនាទីតាំងនៃចំណុចនិយាមកាលើផែនទី

## ៤-៤ ការបង្កើត និង គ្រប់គ្រងប្រព័ន្ធទុកដាក់ឯកសារ

គ្រូបណ្តុះបណ្តាលនឹងធ្វើបទបង្ហាញដល់សិក្ខាកាមអំពីៈ

- ការបង្កើតប្រព័ន្ធទុកដាក់ឯកសារ
  - ការសំគាល់ឯកសារដែលបានរៀបចំ
  - ការចាត់ថ្នាក់ឯកសារ
- ការថែរក្សាប្រព័ន្ធទុកដាក់ឯកសារ
  - ការចាត់ចែងឯកសារ
- ការធ្វើសារពើភ័ណ្ឌប្រព័ន្ធឯកសាររបស់អ្នក

## ឯកសារយោង :


- កំណត់ត្រាសង្ខេបលេខ ១ ស្តីពីការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ អភិបាលកិច្ច និង ពាណិជ្ជកម្ម ( សេរីឆ្នាំ ២០០៧)
- ក្រមបច្ចេកទេសប្រមូលព្រៃឈើនៅកម្ពុជា ( ឆ្នាំ ១៩៩៩)
- សារាចរលេខ ០២ សរ ចុះថ្ងៃទី ២៦-០២-២០០៧ របស់រាជរដ្ឋាភិបាល ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- ក្រមនីតិវិធីព្រហ្មទណ្ឌ ( ឆ្នាំ ២០០៧)
- អនុសញ្ញាស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និង រុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ( សាយតេស) ( ឆ្នាំ ១៩៧៣ និង ១៩៧៩)
- ប្រកាសរួមលេខ ០៩៧ ប្រក.កសក-កយ/០៦ ចុះថ្ងៃទី ០៦-០៣-២០០៦ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ក្រសួងយុត្តិធម៌ ស្តីពីទំរង់បែបបទនៃកំណត់ហេតុបទល្មើសព្រៃឈើ
- ច្បាប់ស្តីពីព្រៃឈើ ( ឆ្នាំ ២០០២)
- គំរោងពង្រឹងសមត្ថភាពការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង អភិបាលកិច្ចនៅក្នុងប្រទេសកម្ពុជា លេខ ITTO-PD493/07 Rev.1 (F) ( ឆ្នាំ ២០០៨)
- ច្បាប់ភូមិបាល ( ឆ្នាំ ២០០១)
- ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវ ( ឆ្នាំ ២០០៥)
- ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ( ឆ្នាំ ២០០៨)
- ច្បាប់ស្តីពីការគ្រប់គ្រងធនធានរ៉ែ និង ការធ្វើអាជីវកម្ម ( ឆ្នាំ ២០០៧)
- ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក ( ឆ្នាំ ២០០៧)
- បទបញ្ជាលេខ ០១ បប ចុះថ្ងៃទី ០៩-០៦-២០០៤ របស់រាជរដ្ឋាភិបាល ស្តីពីការទប់ស្កាត់ បង្រ្កាប និង លុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និង ការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ
- បទបញ្ជាលេខ ០១ បប ចុះថ្ងៃទី ១០-០៥-២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការទប់ស្កាត់ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិ
- បទបញ្ជាលេខ ០២ បប ចុះថ្ងៃទី ២០-០៩-២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រង និង ត្រួតពិនិត្យលើការប្រើប្រាស់រណារយន្តកាត់-អារឈើ
- របាយការណ៍ស្តីពីការវាយតំលៃធនធានមនុស្សរបស់រដ្ឋបាលព្រៃឈើមូលដ្ឋានសំរាប់តំរូវការបណ្តុះបណ្តាល ( លោក ពិន ផាន់នី ឆ្នាំ ២០០៩)
- ប្រកាសលេខ ០៨៩ ប្រក.កសក ចុះថ្ងៃទី ១៤-០២-២០០៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពី ផល អនុផលព្រៃឈើដែលត្រូវហាមឃាត់ការប្រមូលផល

- ប្រកាសលេខ ០២០ ប្រក.កសក ចុះថ្ងៃទី ២៥-០១-២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពី ចំណាត់ថ្នាក់ និងបញ្ជីឈ្មោះប្រភេទសត្វព្រៃ
- ប្រកាសលេខ ៥៥០ ប្រក.កសក ចុះថ្ងៃទី ១៧-១២-២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកែសំរួលការកែសំរួលឈ្មោះប្រភេទសត្វព្រៃចំនួន ៥ប្រភេទ និងធ្វើចំណាត់ថ្នាក់សត្វព្រៃចំនួន ៦ ប្រភេទក្នុងឧបសម្ព័ន្ធនៃប្រកាសលេខ ០២០ ប្រក.កសក ចុះថ្ងៃទី ២៥-០១-២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- ទំរង់របាយការណ៍ស៊ើបអង្កេតដំបូងលើបទល្មើសព្រៃឈើ (រដ្ឋបាលព្រៃឈើ ឆ្នាំ ១៩៩៩)
- សុន្ទរកថារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីបិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ ២០០៨-២០០៩ និង ទិសដៅឆ្នាំ ២០១០ ស្តីពីការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ និង ចំណាត់ការឱ្យបានឆាប់រហ័សនូវសំណុំរឿងបទល្មើសព្រៃឈើ
- អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩-០៣-២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- អនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧-១២-២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- អនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ២៩-០៥-២០០៦ ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និង រុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់
- អនុក្រឹត្យលេខ ១៥៨ អនក្រ.បក ចុះថ្ងៃទី ១៤-១០-២០០៨ ស្តីពីនីតិវិធី និង លក្ខខណ្ឌការគ្រប់គ្រង ការប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវរបស់កងយុទ្ធពលខេមរភូមិន្ទ កងកំលាំងនគរបាលជាតិ ស្ថាប័នសាធារណ: និង មន្ត្រី
- គោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីការប្រើប្រាស់កំលាំង និង អាវុធ ដោយមន្ត្រីអនុវត្តច្បាប់ ដែលគោលការណ៍នេះបានផ្តល់ពតិមានអំពីស្ថានភាពនៅពេលដែលមន្ត្រីអនុវត្តច្បាប់អាចផ្ទុះអាវុធបាន

~~~~~~~~~~~~~~~~~~~~~
~~~~~~~~~~~~~~~~~~~~~